*រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីកិច្ចប្រជុំក្រុមការងារបច្ចេកទេស សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

(Public Financial Management Technical Working Group "PFMTWG")

**(ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦)**

នៅព្រឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេស សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Technical Working Group "PFMTWG") ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ សមាជិក និងមន្ត្រី ពីគ្រប់ក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងតំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ។

គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីពិភាក្សា និងអនុម័តលើប្រធានបទសំខាន់ៗ ចំនួន ០២ រួមមាន÷

**១. របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៦**

អង្គប្រជុំបានឯកភាពលើរបាយការណ៍វឌ្ឍនភាពសមិទ្ធកម្ម ដែលបានបង្ហាញជូន ដោយក្នុងនោះ លទ្ធផលសម្រេចបានជាវិជ្ជមាន មានច្រើននៅតាមផ្នែកសំខាន់ៗ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចជា÷

***ក. បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា÷*** លំហូរចំណូលនិងចំណាយថវិកាកាន់តែរលូន, ការទូទាត់សាច់ប្រាក់កាន់តែមានភាពល្អប្រសើរ ព្រមទាំង កាត់បន្ថយបានទាំងស្រុងនូវបញ្ហាបំណុលកកស្ទះ ។

***ខ. បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ÷*** កិច្ចការសំខាន់ៗ និងចាំបាច់មួយចំនួនត្រូវបានបន្តពង្រឹងនិងបញ្ចប់ជាពិសេស ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System) ឱ្យបានសម្រេចតាមគោលដៅ ទន្ទឹមនឹងត្រូវរៀបចំបញ្ចប់ការងារជាមូលដ្ឋានដែលនៅសេសសល់នៅក្នុងដំណាក់កាលទី ១ ដើម្បីឈានឆ្ពោះទៅអនុវត្តដំណាក់កាលទី ២ នៅក្នុងឆ្នាំ ២០១៧ ខាងមុខនេះ ។

***គ. ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ÷*** គឺជាគោលដៅស្នូលនៃដំណាក់កាលទី៣ ដែលក្នុងនោះការងារអាទិភាពមួយចំនួនត្រូវបានពង្រឹងនិងពង្រីក ដូចជា ការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកានៅតាមក្រសួង-ស្ថាប័ន, ការពិនិត្យកែសម្រួលនិងរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៧-២០២៥ និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ ។

***ឃ. ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់÷*** បានពិនិត្យនិងរៀបចំក្របខ័ណ្ឌថវិកា ក្របខ័ណ្ឌគណនេយ្យភាព និងក្របខណ្ឌសវនកម្មផ្អែកលើសមិទ្ធកម្មដែលផ្សារភ្ជាប់ការចំណាយសម្រាប់កម្មវិធីនីមួយៗ ។

**ង. ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព÷** ពង្រឹងនិងពង្រីកភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង សមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ការទទួលខុសត្រូវ និងមានសមានគតិភាពជាមួយនឹងការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ និងដំណាក់កាលបន្ទាប់ ។

ជាមួយគ្នានេះ ជារួម, តំណាងដៃគូអភិវឌ្ឍន៍បានសាទរដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នាពេលនេះ និងកិច្ចប្រជុំប្រចាំឆ្នាំ នាពេលខាងមុខ ដោយបានផ្តល់នូវមតិកែលម្អមួយចំនួនលើកិច្ចការងារកែទម្រង់កន្លងមក ទាំងការងារត្រៀមរៀបចំសម្រាប់ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)ផង ក៏ដូចជាកិច្ចដំណើការនៃការកែទម្រង់ប្រព័ន្ធថវិកាផង សម្រាប់ជាប្រយោជន៍ដល់ការអនុវត្តការងារនេះនៅជំហានបន្ទាប់ និងបានប្តេជ្ញាចិត្ត ក្នុងការបន្តគាំទ្ររាជរដ្ឋាភិបាល លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ លើសពីនេះ, តំណាងដៃគូអភិវឌ្ឍន៍ បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលសម្រេចបានជារួម នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ដែលសម្រេចបាននៅក្នុងត្រីមាសទី ៣ ក្នុងឆ្នាំ ២០១៦ នេះ ជាពិសេសវឌ្ឍនភាព នៃការអនុវត្តសកម្មភាពសម្រាប់ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការបន្តពង្រឹងការប្រមូលចំណូល ដែលជាទូទៅតំណាងដៃគូ បានវាយតម្លៃថាមានវឌ្ឍនភាពគួរជាទីមោទនៈ ។

**២. វឌ្ឍនភាពការកែសម្រួលផែនការសកម្មភាពរួមដំណាក់កាលទី ៣** (CAP3)

ផែនការសកម្មភាពរួមដំណាក់កាលទី ៣ (CAP3) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានកែសម្រួលនិងដាក់ចេញជា ***៥ ផ្នែក ,២១ គោលបំណង និង ៦៨ ចង្កោមសកម្មភាព*** ដែលតម្រូវឱ្យគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំផែនការសកម្មភាពលម្អិតទៅតាមគោលបំណង និងចង្កោមសកម្មភាព នៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី ៣ (Consolidated Action Plan 3 "CAP3") ដែលពាក់ព័ន្ធនឹងមុខងារនិងភារកិច្ចរបស់សាមីអង្គភាព ដើម្បីគាំទ្រដល់ការអនុវត្តនៃកម្មវិធីកែទម្រង់ដំណាក់កាលទី ៣ ***ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*** ។

ជារួម, លទ្ធផលនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានប្រមូលនូវធាតុចូលសំខាន់ៗបន្ថែមទៀត និងបានអនុម័តរួមគ្នាលើគោលការណ៍ និងខ្លឹមសារឯកសារសម្រាប់ជាប្រធានបទនៃកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដោយឯកឧត្តមបណ្ឌិត **អួន ព័ន្ធមុនីរ័ត្ន** បានផ្តល់អនុសាសន៍ និងណែនាំជាវិធានការណ៍សម្រាប់អនុវត្តបន្ត ដោយបានសំណូមពរដល់គ្រប់ភាគីពាក់ព័ន្ធ ជាពិសេសតំណាងដៃគូអភិវឌ្ឍន៍ទាំងអស់បន្តជួយគាំទ្ររាជរដ្ឋាភិបាល លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាកម្មវិធីកែទម្រង់ធំៗដ៏ទៃទៀត ដែលមានភាពប្រទាក់ក្រឡាគ្នា និងកំពុងបំពេញឱ្យគ្នា ។ ទន្ទឹមនេះ **ឯកឧត្តមបណ្ឌិត** ក៏បានអំពាវនាវដល់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ បន្តការយកចិត្តទុកដាក់ខ្ពស់ ក្នុងការចូលរួមអនុវត្តកម្មវិធីកែទម្រង់នេះ ជាពិសេសការពិនិត្យនិងធ្វើបច្ចុប្បន្នភាព ផែនការសកម្មភាពរួមដំណាក់កាលទី ៣ (CAP3) ដើម្បីគាំទ្រដល់ការអនុវត្តនៃកម្មវិធីកែទម្រង់ដំណាក់កាលទី៣ ***ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*** ដែលជាកម្មវិធីជាអាទិភាពមួយក្នុងចំណោមកម្មវិធីកែទម្រង់ចម្បងទាំងបីរបស់រាជរដ្ឋាភិបាល ៕